ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៦៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតគណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ត្រូវបានបង្កើត **គណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន** ដែលសរសេរជាអក្សរកាត់ថា «**គ.គ.ស.**» ដើម្បីដោះស្រាយជាខ្សែច្រវាក់ពីដើមខ្សែរហូតដល់ចុងខ្សែក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន សំដៅសម្រេចបាននូវការកែច្នៃសំរាម សំណល់រឹងក្នុងស្រុកផលិតជាថាមពលអគ្គិសនី ។

មាត្រា ២.-

គ.គ.ស. មានភារកិច្ចដូចតទៅៈ

កម្រិតទី១ៈ គោលនយោបាយ

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព និងយន្តការតាមដានការអនុវត្ត
- កសាងក្របខណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត
- គិតគូរអំពីយន្តការលើកទឹកចិត្តនានាដល់ការវិនិយោគលើវិស័យកែច្នៃសំរាម សំណល់រឹងផលិតជាថាមពលអគ្គិសនី (តាមទម្រង់ណាមួយដែលសមស្រប និងប្រកបដោយប្រសិទ្ធភាព) និង
- គិតគូរអំពីយន្តការលើកទឹកចិត្តនានា ឱ្យមានការប្រើប្រាស់ផលិតផលដែលមានផលប៉ះពាល់តិច ឬគ្មានដើម្បីកាត់បន្ថយការប្រើប្រាស់ផលិតផលណាដែលនាំឱ្យមានផលប៉ះពាល់ខ្លាំងដល់បរិស្ថាន ។

កម្រិតទី២ៈ ប្រតិបត្តិការ

- សិក្សាបទពិសោធន៍របស់បណ្តាប្រទេសនានាក្នុងតំបន់ ឬប្រទេសអភិវឌ្ឍន៍ដទៃទៀតដែលមានឧត្តមានុវត្តន៍ក្នុងការគ្រប់គ្រងសំរាម សំណល់រឹង រួមទាំងការកែច្នៃសំណល់រឹង និងការបំប្លែងទៅជាថាមពលអគ្គិសនី
- លើកអនុសាសន៍ជាវិធានការ និងដឹកនាំ សម្របសម្រួល ព្រមទាំងតាមដានការអនុវត្តការកែទម្រង់របៀបនៃការគ្រប់គ្រងក្រុមហ៊ុនប្រមូលសំរាម សំណល់រឹងនាពេលបច្ចុប្បន្ន ព្រមទាំងយន្តការបង់ថ្លៃទូទាត់សេវា និងកំណត់នីតិវិធីដោះស្រាយបញ្ហាឱ្យបានច្បាស់លាស់ជាស្ថាពរ និង
- ធ្វើយុទ្ធនាការអប់រំ និងផ្សព្វផ្សាយទ្រង់ទ្រាយធំទូទាំងប្រទេស សំដៅកែប្រែឥរិយាបថរបស់ប្រជាពលរដ្ឋ ។

ជំពូកទី២
សមាសភាព និងរចនាសម្ព័ន្ធ

មាត្រា ៣.-

គ.គ.ស. មានសមាសភាពដូចខាងក្រោមៈ

១. រដ្ឋមន្ត្រីក្រសួងបរិស្ថាន	ប្រធាន
២. រដ្ឋលេខាធិការ/អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន	អនុប្រធាន
៣. រដ្ឋលេខាធិការ /អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	អនុប្រធាន
៤. រដ្ឋលេខាធិការ/អនុរដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល	សមាជិក
៥. រដ្ឋលេខាធិការ/អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍	សមាជិក
៦. រដ្ឋលេខាធិការ/អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន	សមាជិក

៧. រដ្ឋលេខាធិការ/អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម សមាជិក
៨. រដ្ឋលេខាធិការ/អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា សមាជិក
៩. រដ្ឋលេខាធិការ/អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក
១០. រដ្ឋលេខាធិការ/អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក
១១. អគ្គលេខាធិការ/អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក
១២. ប្រធាន/អនុប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា សមាជិក
១៣. អគ្គនាយក/អគ្គនាយករងអគ្គិសនីកម្ពុជា សមាជិក
១៤. អភិបាល/អភិបាលរងរាជធានីភ្នំពេញ សមាជិក
១៥. អគ្គនាយកនៃអគ្គនាយកដ្ឋានគាំពារបរិស្ថានក្រសួងបរិស្ថាន សមាជិកអចិន្ត្រៃយ៍ ។

គ.គ.ស. អាចមានសមាសភាពបន្ថែម ជារដ្ឋមន្ត្រី ប្រធានស្ថាប័ន ឬ តំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀតនៃរាជរដ្ឋាភិបាល តាមការចាំបាច់ ។

សមាសភាពជាក់ស្តែងនៃ **គ.គ.ស**. ត្រូវកំណត់ដោយសេចក្តីសម្រេច ។

មាត្រា ៤.-

គ.គ.ស. អាចមានគណៈកម្មាធិការ អនុគណៈកម្មាធិការ ឬក្រុមការងារផ្សេងៗ ដើម្បីបម្រើការងារក្នុងការបំពេញភារកិច្ចដូចមានចែងក្នុងមាត្រា ២ ខាងលើ តាមតម្រូវការចាំបាច់ ។ គណៈកម្មាធិការ អនុគណៈកម្មាធិការ ឬក្រុមការងាររបស់ **គ.គ.ស**. ត្រូវបង្កើតឡើងដោយអនុក្រឹត្យ ឬ សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើរបស់ប្រធាន **គ.គ.ស**. ។

ជំពូកទី៣
ការប្រព្រឹត្តទៅនៃ គ.គ.ស.

មាត្រា ៥.-

តាមការអញ្ជើញរបស់ប្រធាន អនុប្រធាន និងសមាជិក **គ.គ.ស**. ត្រូវចូលរួមប្រជុំ ឬចាត់តំណាងមានសិទ្ធិសម្រេចជំនួស ដើម្បីចូលរួមប្រជុំ ក្នុងករណីអវត្តមាន ឬមានធុរៈ ។

គ.គ.ស. ប្រើប្រាស់ត្រារបស់ក្រសួងបរិស្ថាន សម្រាប់ដំណើរការការងារ ។

មាត្រា ៦.-

ប្រធាន **គ.គ.ស**. មានសិទ្ធិអញ្ជើញប្រធានស្ថាប័ន ឬតំណាងប្រធានស្ថាប័ន ឬអាជ្ញាធរ ព្រមទាំងមន្ត្រីបច្ចេកទេសនៃក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ចូលរួមប្រជុំ និងបំពេញការងារស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងអនុក្រឹត្យនេះ ។

មាត្រា ៧.-

គ.គ.ស. ព្រមទាំងគណៈកម្មាធិការ អនុគណៈកម្មាធិការ និងក្រុមការងារបច្ចេកទេស មានសិទ្ធិអញ្ជើញតំណាងដៃគូអភិវឌ្ឍន៍ តំណាងវិស័យឯកជន តំណាងសង្គមស៊ីវិល ទីប្រឹក្សា ឬអ្នកជំនាញការជាតិ និងអន្តរជាតិចូលរួមប្រជុំ ក្នុងឋានៈជាសមាជិក អ្នកសង្កេតការណ៍ ឬអ្នកផ្តល់យោបល់ តាមការចាំបាច់ ។

មាត្រា ៨.-

គ.គ.ស. មានអគ្គលេខាធិការដ្ឋានមួយ ជាសេនាធិការសម្រាប់បំពេញមុខងាររបស់ខ្លួន ។ អគ្គលេខាធិការដ្ឋានដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងពីររូប និងទីប្រឹក្សាមួយរូប ព្រមទាំងអ្នកស្រាវជ្រាវ ជំនួយការអ្នកស្រាវជ្រាវ និងមន្ត្រីមួយចំនួនតាមការចាំបាច់ ។

អគ្គលេខាធិការ អគ្គលេខាធិការរង និងទីប្រឹក្សាត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

អ្នកស្រាវជ្រាវ ជំនួយការអ្នកស្រាវជ្រាវ និងមន្ត្រី នៃអគ្គលេខាធិការដ្ឋាន **គ.គ.ស.** ត្រូវតែងតាំងដោយអនុក្រឹត្យ ឬប្រកាស អនុលោមតាមបទប្បញ្ញត្តិជាធរមាន ។

មាត្រា ៩.-

ប្រភពធនធានសម្រាប់ទ្រទ្រង់អគ្គលេខាធិការដ្ឋាននៃ **គ.គ.ស.** រួមមាន ប្រភពថវិកាជាតិ ថវិកាដៃគូ និងប្រភពស្របច្បាប់ផ្សេងទៀត ។

មាត្រា ១០.-

ក្នុងការបំពេញមុខងារជាសេនាធិការបច្ចេកទេសរបស់ **គ.គ.ស.** អគ្គលេខាធិការដ្ឋាន មានភារកិច្ចដូចតទៅ៖

- រៀបចំតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនានាពាក់ព័ន្ធការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- សហការ និងសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានា ដើម្បីតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនានាពាក់ព័ន្ធការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- រៀបចំកិច្ចប្រជុំរបស់ **គ.គ.ស.** តាមការណែនាំរបស់ប្រធាន **គ.គ.ស.**
- រៀបចំកំណត់ហេតុអង្គប្រជុំ និងធ្វើសេចក្តីជូនដំណឹង ស្តីពីការសម្រេចរបស់ **គ.គ.ស.** និងសេចក្តីជូនដំណឹង ស្តីពីការសម្រេចរបស់រាជរដ្ឋាភិបាលលើសំណើ និងអនុសាសន៍នានារបស់ **គ.គ.ស.** ដល់សមាជិក **គ.គ.ស.** និងអង្គភាពពាក់ព័ន្ធក្រោមឱវាទរបស់ **គ.គ.ស.**
- សម្របសម្រួលការងារប្រចាំថ្ងៃរបស់ **គ.គ.ស.** ស្របតាមការណែនាំ និងការសម្រេចរបស់ប្រធាន **គ.គ.ស.** និង
- បំពេញការងារផ្សេងៗទៀត តាមការណែនាំរបស់ប្រធាន **គ.គ.ស.** ។

ជំពូកទី៤
អវសានប្បញ្ញត្តិ

មាត្រា ១១.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

/

មាត្រា ១២.-

ប្រធាន **គ.គ.ស.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃអង្គារ ៥ កើត ខែ ផល្គុន ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី

និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ